# សេចក្តីជូនដំណឹងស្តីពីជំងឺផ្តាសាយបក្សី
# របស់ក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោក

ក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោក សូមជំរាបជូនបងប្អូនប្រជាពលរដ្ឋខ្មែរទូទាំងប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា ដោយយោងទៅលើជំងឺផ្តាសាយបក្សីទើបតែផ្ទុះឡើងវិញ ដែលកើតលើមនុស្សនៅក្នុងខេត្តកណ្តាល និង យោងទៅលើបទពីសោធន៍កន្លងមកជំងឺផ្តាសសាយបក្សីតែងតែកើតមាននៅរដូវរំហើយជាពិសេសនៅចន្លោះពីខែធ្នូ ដល់ខែមេសា ហើយដែលកន្លងមកបណ្តាលឱ្យប្រជាពលរដ្ឋចំនួន៨នាក់បានកើតជំងឺផ្តាសាយបក្សីដែលក្នុងនោះ ៧ករណីបានស្លាប់ ។

ដោយមានការចម្លងរោគដ៏កាចសាហាវនេះ ហើយដែលបានកើតឡើងជារៀងរាល់ឆ្នាំនៅក្នុងប្រទេសយើង ក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោកប្រចាំនៅព្រះរាជាណាចក្រកម្ពុជា សូមអំពាវនាវដល់ប្រជាពលរដ្ឋទូទាំងប្រទេសឱ្យមានការប្រុងប្រយ័ត្នខ្ពស់ចំពោះជំងឺនេះ និងសូមអនុវត្តន៍នូវសារអប់រំសុខភាពដូចខាងក្រោម:

- មិនត្រូវរើសយកមាន់ ឬទាដែលមានជំងឺឬងាប់ ដោយយថាហេតុនៅក្នុងភូមិមកធ្វើជាអាហារនោះទេ និងត្រូវរាយការណ៍ជាបន្ទាន់ទៅអ្នកស្ម័គ្រចិត្តភូមិ ឬអាជ្ញាធរដែនដីដែលនៅជិតបំផុត
- មិនត្រូវឱ្យកុមារប៉ះពាល់មាន់ ទា ឬសត្វស្លាបផ្សេងៗទៀតជាពិសេស សត្វស្លាបដែលឈឺឬងាប់
- ត្រូវលាងដៃរាល់ពេលក្រោយ ជូតសំបោរ ឬចាប់កាន់សត្វ ចិញ្ចឹមគ្រប់ប្រភេទ និងលាងដៃមុនរាល់ពេលទទួលទានអាហារ ។
- បរិភោគសាច់ សត្វស្លាប ឬស៊ុតត្រូវរៀបចំ ចំអិនអោយបានឆ្អិនល្អ (ឆ្អិនគ្រប់ផ្នែកទាំងអស់ នៃសាច់សត្វស្លាប )
- ហាមកុំឱ្យបឺត ឬ ជញ្ជក់ក្បាលមាន់ជុល
- ពេលកណ្តាស. ក្អក ត្រូវយកកន្សែងដៃ ឬក្រមាមកខ្ទប់មុខ ដើម្បីជៀសវាងរបាចសាចទឹកមាត់ទឹកសំបោរទៅលើអ្នកដទៃ តែបើគ្មាន កន្សែងដៃ ឬក្រមាខ្ទប់មុខទេ យើងត្រូវយកដៃខ្ទប់មាត់ បន្ទាប់មកលាងដៃនិងសាប៊ូ
- ចំពោះអ្នកចិញ្ចឹម, អ្នកដឹកជញ្ជូនអ្នកសំលាប់ និងអ្នកលក់សត្វបក្សីត្រូវពាក់ម៉ាស់, ស្បែកជើងកវែង និងស្រោមដៃក្នុងពេល:
    - o ចេញនិងចូលកសិដ្ឋានចិញ្ចឹមសត្វ
    - o ពេលដឹកជញ្ជូនសត្វបក្សី តាមរថយន្ត ឬតាមម៉ូតូ
    - o ពេលដំណើរការសំលាប់សត្វបក្សី ជាអាជីព នៅក្នុងទីផ្សារ និងទីសាធារណៈ

- ពេលអនុវត្តន៍ការងារចាងលើនេះរួច ត្រូវប្រញាប់លាងដៃនិងងូតទឹកជំរះរាងកាយជាមួយសាប៊ូ ចំណែកសំលៀកបំពាក់ និងឧបករណ៍ការងារ ត្រូវយកទៅត្រាំក្នុងទឹកជាមួយសាប៊ូ រួចយកទៅហាលថ្ងៃឱ្យស្ងួត ។
- ត្រូវជ្រើសរើសទិញសាច់មាន់ ទា និងស៊ុតពីកន្លែងដែលមានការទទួលខុសត្រូវ និងធានា ឬមកពីប្រភពដែលជឿជាក់បាន និងជ្រើសរើសសាច់មាន់ស្រស់ថ្មី គ្មានស្នាមជាំខ្មៅ ចំណែកស៊ុតត្រូវមើលឱ្យស្រស់ថ្មីគ្មានលាមកមកជាប់សំបក ។
- នៅពេលរៀបចំ ចំអិនអាហារមិនត្រូវវាសដៃទៅលើច្រមុះ ភ្នែក មាត់ និងប៉ះពាល់សំភារៈផ្សេងៗទៀតដូចជាទូរស័ព្ទដៃជាដើមឡើយ ។
- បើសិនជាអ្នកជំងឺ សង្ស័យថាមានជំងឺផ្តាសាយបក្សី សូមបងប្អូនអនុវត្តន៍នូវវិធានការដូចខាងក្រោមនេះ៖
  - o បញ្ជូនអ្នកជំងឺទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែកដែលនៅជិតចំផុតដើម្បីពិនិត្យព្យាបាលឱ្យទាន់ពេលវេលា ។
  - o សូមកុំផ្តល់ឱសថ សាស្ពីរីនដល់អ្នកជំងឺជាកុមារ
  - o នៅពេលថែទាំអ្នកជំងឺត្រូវជៀសវាងការប៉ះពាល់ជិតស្និត ជាមួយអ្នកជំងឺ ដូចជាការឱប ឬថើប ជាដើម ។
  - o សូមណែនាំដល់អ្នកជំងឺអោយពាក់ម៉ាស ឬក្រមា ឱ្យជិតទាំងមាត់ និងច្រមុះ ហើយសំរាប់អ្នកថែទាំក៏ត្រូវពាក់ម៉ាស់ការពារខ្លួនដែរ ។
  - o សូមទំនាក់ទំនងទូរស័ព្ទលេខ : ០១២ ៤៨៨ ៩៨១, ០១២ ៨៣៦ ៨៦៨

អាស្រ័យហេតុនេះ សូមបងប្អូនទាំងអស់ បង្កើនការយកចិត្តទុកដាក់តំរិតខ្ពស់នៅក្នុងការការពារជាមុនដោយអនុវត្តតាមសេចក្តីជូនដំណឹងឬតាមរយៈការអប់រំសុខភាព និងការផ្សព្វផ្សាយព័ត៌មានដើម្បីធ្វើយ៉ាងណាកាត់ បន្ថយឱ្យនៅជាអប្បបរមានូវការកើតមានឡើងនូវជំងឺកាចសាហាវនេះ ។ ក្រសួងសុខាភិបាល និងអង្គការ សុខភាពពិភពលោកសង្ឃឹមនិងជឿជាក់យ៉ាងមុតមាំលើការយកចិត្តទុកដាក់ចំពោះសេចក្តីជូនព័ត៌មានដ៏មាន សារៈសំខាន់នេះ ។

ព័ត៌មានបន្ថែម សូមទាក់ទងមកក្រសួងសុខាភិបាល:

- វេជ្ជបណ្ឌិត សុខ ទូច ទូរស័ព្ទលេខ: ៨៥៥ ១២ ៨៥៦ ៨៤៨
- វេជ្ជបណ្ឌិត លី សូវ៉ាន់ ទូរាស័ព្ទលេខ: ៨៥៥ ១២ ៨២៥ ៤២៤

អង្គការសុខភាពពិភពលោក:

វេជ្ជបណ្ឌិត ម៉ៃឃើល អូលៀរី ទូរស័ព្ទលេខ: ៨៥៥ ១២ ៩៧៦ ៩៧៦ ឬ

វេជ្ជបណ្ឌិត នីម៉ា អាហ្កាវី ទូរស័ព្ទលេខ: ៨៥៥ ១២ ៩៤៣ ៨៧៧